# ការសម្ភាសរបស់ អ៊ី អ៊ុក ចាន់ធឿន

កៈ អ្នកធ្វើការសំភាសន៍ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍អ៊ុក ចាន់ធឿន

កៈ ជាដំបូងសូមជំរាបសួរសូមជំរាបសួរអ៊ី!!

ខៈ ចាស!ជំរាបសួរ!

កៈ
ចាស!អ៊ីថ្ងៃនេះខ្ញុំមានឪកាសផ្ទាល់ដើម្បីនឹងសំភាសន៍អ៊ីខ្ញុំសូមណែនាំថាខ្ញុំមកពីសាលាដែលខ្ញុំបានធ្វើការជាមួយនឹងគំរោងរបស់សាលាBYUHawai
ចឹងថ្ងៃនេះខ្ញុំមានឪកាសដើម្បីមកសំភាសន៍អ៊ីសួរនូវប្រវត្តិរបស់អ៊ីនឹងបទពិសោធន៍របស់អ៊ីផ្ទាល់ដែលអ៊ីភ្លាប់បានឆ្លងកាត់កន្លងមក
ហើយពេលដែលបានសំភាសន៍អ៊ីហើយយើងនឹងយកសំលេងរបស់អ៊ីរក្សាទុកដើម្បីអោយកូនចៅជំនាន់ក្រោយគេបានដឹងហើយសំលេងនឹងអ្នកដែលគេចង់ស្តាប់នឹងគេគ្រាន់តែចូលទៅកាន់អ៊ីនធឺណែតហើយគេវាយឈ្មោះរបស់អ៊ីនឹងចូលទៅកាន់វេបសាយខាងសាលាទៅគេនឹងអាចស្តាប់សំលេងរបស់អ៊ីបានហើយ។
ចឹងថ្ងៃនេះខ្ញុំមានឪកាសល្អមែនទែនដែលបានមកសំភាសន៍អ៊ីផ្ទាល់ចឹងអ៊ីអនុញ្ញាតអោយខ្ញុំធ្វើការសំភាសន៍អ៊ីដែលឬទេថ្ងៃនេះ?

ខៈ ចាស!អោយ។

កៈ
ចាស!ថ្ងៃនេះគឺជាថ្ងៃទី២៥ខែ៥ឆ្នាំ២០១៨ចឹងខ្ញុំមានឪកាសដើម្បីនឹងសំភាសន៍អ៊ីផ្ទាល់ចឹងអ៊ីមានឈ្មោះអ្វីដែល?

ខៈ ចាស!ខ្ញុំឈ្មោះអ៊ុក ចាន់ធឿន។

កៈ ចាស!ចឹងឈ្មោះនឹងត្រូវនឹងអត្តសញ្ញាណប័ត្ររបស់អ៊ីដែលឬទេ?

ខៈ ចាស!ត្រូវតើ!!

ក៖ ឈ្មោះពេញរបស់អ៊ីនឹងឈ្មោះអ៊ុកចាន់ធឿននឹងតែម្តង?

ខ៖ ចាស!!

ក៖ ចាស!ចឹងឆ្នាំនឹងអ៊ីមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ឆ្នាំនឹងអ៊ីមានអាយុ៥២ឆ្នាំហើយ។

ក៖ ចាស!អ៊ីមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែលឬទេ?

ខ៖ទេខ្ញុំនឹងមិនសូវជាបានចាំដែលនឹងទាល់តែមើលនៅក្នុងអត្តសញ្ញាណប័ត្រឯណោះទាល់តែទៅមើលក្នុងក្រដាសអ៊ីន៎។

ក៖ ចឹងអ៊ីមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងនៅក្នុងឆ្នាំខ្មែរដូចជាឆ្នាំចន្ទ័គតិសុរិយៈគៈតិអីដែរឬទេ?

ខ៖
អត់ទេមិនសូវជាចាំទេដូចថាយើងនឹងរៀនមិនសូវបានច្រើនដូចថាជីវៈភាពម្តាយឪពុកយើងនឹងនៅក្រ។

ក៖ ចាស!!

ខ៖ ចឹងមិនសូវរៀនបានទេបានតែរៀនអីតិចតួចនឹងណាយើងបានរៀនតែមើលអីបានតិចតួចរៀនមិនបានសូវជ្រៅជ្រះទេចឹង។

ក៖ ចុះអ៊ីមានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែលឬទេ?

ខ៖ អត់ទេទាល់តែទៅមើលបើចឹងខ្ញុំមិនចាំទេ។

ក៖ ចាស!!!

ខ៖ យើងវាដូចថាយើងវាគិតច្រើនចឹងធ្វើអោយយើងនឹងបាត់ការចង់ចាំចឹងណា....

ក៖ ចាស!!!

ខ៖
វាដូចថាធ្វើអោយយើងនឹងវាមិនចាំដូចថាយើងនឹងវាមានកូនច្រើនចឹងទៅវាបានធ្វើអោយយើងនឹងមិនសូវជាចង់ចាំ។

ក៖ ចាស!!!

ខ៖ ចាស!ចឹងហើយទៅបានជាយើងនឹងវាមិនសូវជាបានចាំ។

ក៖ ចាស!ចឹងអ៊ីសព្វថ្ងៃនឹងអ៊ីមានកូនប៉ុន្មាននាក់ហើយ?

ខ៖ ចាស!ខ្ញុំមានកូន៨នាក់។

ក៖ ចាស!អ៊ីមានកូន៨នាក់ហើយ។គាត់មានឈ្មោះអីខ្លះទៅអ៊ី?

ខ៖ កូនៗរបស់អ៊ីហាស់?

ក៖ ចាស!អ៊ី!!

ខ៖ កូនខ្ញុំនឹងមីងបងមានឈ្មោះ ភីន ចានដា ទី២ឈ្មោះភីនខួច ទី៣ ភីន ស្រស់ ទី៤ភីនស្រីម៉ៅ ហើយទី៥ឈ្មោះភីនសុភ័ក្រ ទី៦ភីនសុខភណ្ឌ័ ទី៧ ភីន សុសំភស ទី៨ ភីន មករា។

ក៖ ចាស!ចឹងពួកគាត់ទាំងអស់គ្នានឹងគាត់មានស្រីប៉ុន្មានហើយប្រុសប៉ុន្មានដែរ?

ខ៖ ស្រី៥ប្រុស៣នាក់។

ក៖ ចាស!ហើយពួកគាត់នឹងបានរៀនបានកំរិតណាសំរាប់កូននិមួយៗរបស់អ៊ី?

ខ៖ បើនិយាយទៅអូនអើយ កូននឹងម៉ែ អោយវាបានរៀនហើយក៏ប៉ុន្តែជីវៈភាពយើងនឹងវានៅខ្វះខាតតិចតួចដល់ចឹងទៅ អោយវា រៀនចឹងទៅប៉ុន្តែវាថាអត់រៀនដល់ចឹងហើយបានជាកូនខ្ញុំនឹងសុទ្ធតែអ្នកដែលមិនសូវចេះចេះបានតែតិចតួចៗចឹងមួយហ៊ឹកនឹងខ្ញុំបានទៅនៅនឹងមុខពេទ្យរ៉ុស៊ី
យើងបានដើរទៅរើសអេបចាយព្រោះតែជីវៈភាពយើងនឹងវាក្រនោះ។
វាវេទនាណាស់តឹមតែបានដល់ពេលដែល
ប្តីខ្ញុំនឹងគាត់ឈឺចឹងទៅបានជាគាត់នឹងទៅនៅជាមួយនឹងឪពុកគាត់នៅឯភ្នំប្រសិទ្ធិនោះ

ហើយពេលនឹងកូនវារៀងធំដុំចឹងទៅបានជាយើងនឹងវាគ្រាន់បើបន្តិចតែវាមិនមានទេ យើងបានម៉ាហូបម៉ាចុកចឹងទៅវាមិនខ្វះខាតនោះទេ។

កៈ ចាស!ចឹងទៅតើពួកគាត់ទាំងអស់គ្នា បានរៀនដល់ថ្នាក់ទី១២ដែរឬទេ?

ខៈ អត់មានទេ កូនខ្ញុំនឹងបានរៀនត្រឹមថ្នាក់ទី៣ទេ គេបានរៀនដល់ថ្នាក់តិចតួចនឹង។

កៈ ចាស!នៅសាលាណាដែរ?

ខៈ នៅសាលាចំរើនផលយើងនឹង។

កៈ ចាស!គឺកូនទាំងអស់រៀននៅសាលានឹង?

ខៈ ចាស!នឹងហើយ។

កៈ
ចាស!ហើយចឹងអ៊ីមានកូនប៉ុន្មាននាក់ហើយដែលមានគ្រួសារហើយបានរៀបអាពាហ៍ពិពាហ៍ហើយ?

ខៈ មានកូនខ្ញុំនឹងវារៀបបានវា៣នាក់ហើយមើលមានកូន៣នាក់នឹងគឺចាន់ដាមួយ ស្រីម៉ៅមួយ ស្រស់មួយនឹងវាឡើងបាន៣នាក់ហើយនៅមានប្រុស១នាក់ទៀតចឹងវាឡើងបាន៤ចឹងរៀបបាន៤នាក់ហើយដល់ពេលថ្ងៃ៣នឹងវាត្រូវរៀបកូន១នាក់ទៀត។

កៈ ចាស!ចឹងសូមអបអរសាទរផងដែលអី។ ចាសចឹងតើគាត់នៅភ្នំពេញឬក៏នៅតាមខេត្ត?

ខៈ ចាស!កាលនឹងរៀបនៅតាមខេត្តនឹង។

កៈ នៅតាមខេត្តណាដែរ?

ខៈ នៅនឹភ្នំពិសិទ្ធយើងនឹង។

កៈ ចាស!ចឹងកូនរបស់អ៊ីទាំង៤នាក់នឹងគាត់មិនទាន់បានរៀបការនៅ៤នាក់ ទៀតចឹងត្រូវអត់?

ខៈ ចាស!!!

ក៖ចាស!ចឹងអឺមានចៅៗដែលកូនអឺបានរៀបការរួចចឹងហើយ
តើពួកគាត់មានឈ្មោះអ្វីខ្លះដែលទៅអឺ?

ខ៖ចៅរបស់ខ្ញុំនឹងគេបានដាក់ឈ្មោះនឹងទៅតាមឈ្មោះរបស់ឪជីតារបស់គេនឹងមួយនឹងមាន
ឈ្មោះថាចៅហានហើយមួយនេះគេមានឈ្មោះថាស្រីសា....

(កាត់សំដីព្រោះមានគេដើរមកសួរ)

ក៖ ចាស! ចឹងពួកគាត់មានឈ្មោះអ្វីខ្លះទៅអឺចៅៗ?

ខ៖ ចាស!មួយឈ្មោះថាលីសាមួយទៀត
មានឈ្មោះថាចៅហានហើយមួយទៀតនឹងគេមានឈ្មោះអឺ
...(កំពុងតែសួរចៅគាត់ដែលបានមកជាមួយគាត់)

ចៅមីងខ្មៅនឹងមានឈ្មោះអ្វីដែល?

គ៖ បាទ?

ខ៖ សួរឈ្មោះ?

គ៖ បាទ?

ខ៖ សួរឈ្មោះ?

ខ៖ អូ!អូនកា

ក៖ ចាស!!អូនការ

គ៖ អាហាំ

ខ៖ អាហាំនឹងហើយៗនៅកូនមីដានឹង
មួយមានឈ្មោះថាមិនកានឹងមួយទៀតនឹងមានឈ្មោះថាអ្វីដែលកូនរបស់មីដានឹង?

គ៖ ឈ្មោះខ្លី

ខ៖ ហាស គេមិនមែនមានឈ្មោះខ្លីទេ។

កៈ ហាហាហាឈ្មោះក្រៅហស់?

ខៈ ឈ្មោះគេជីតា ជីតានឹងអូនអើយកុំថាពេលដែលបានចាក់ភ្លេង(លឺភ្លេងគេនឹងឡើង...)

កៈ អូ!គេចូលចិត្តរាំ អូគេមានទេពកោសលពីកំណើត។

ខៈ វាចឹងហើយនឹងសំដីវិញនឹងឡើងអោយជ្រះ

កៈ ចឹងគេមានដុងខាងសិល្បៈហើយចឹងនោះ។

ខៈ បានថាអោយនឹងខ្ញុំនឹងថាអោយគេថានីតាថៅឯដល់ពេលធំឡើងថៅឯទៅឡើង ចម្រៀងមែនទេថៅ គេថាខ្ញុំនឹង រាំណាយាយ ហើយដល់ពេលហើយទៅគេរាំដាក់អោយមើលឡើងរំពើត។

កៈ ចាស!! ហាហាហើយសប្បាយព្រោះមានថៅចេះចឹង?

ខៈ ដល់ពេលកូនៗនៅឯខេត្តសៀមរាបនឹងគេមិនបានថៅទេបានការហើយ២ឆ្នាំហើយមិនទាន់មានកូនទៀតអាលីង ចឹងក្រៅពីនឹងគេមិនទាន់មានកូន។

កៈ ចាស!! ហ៊ឺ!!

ខៈ គេមិនទាន់មានកូនមានអី។

កៈ ចាស!!!

ខៈ ពិបាកណាស់អូនអើយព្រោះយើងមានប្រវត្តិយើងនឹងវាក្រ ចឹងបានថាធ្វើម៉េចអោយតែបានអោយកូននឹងហូបទៅយើងសុខចិត្តមិនហូបទេសុខចិត្តអោយកូនបានហូបអោយវាបានឆ្អែកទៅតែប៉ុនឹងណា....

កៈ ចាស!!

ខៈ យើងនឹងតស៊ូខ្លួនយើងទៅណាយើងមិនបាច់ទៅពឹងគេ។

កៈ ចាស!ចឹងសព្វថ្ងៃនឹងអ៊ីមានមុខរបរជាអ្វីដែរ?

ខ៖
ខ្ញុំបានលក់អីវ៉ាន់តែបន្តិចនឹងនៅខាងមុខផ្ទះតែបន្តិចនឹងនៅឯជើយភ្នំពិសិទ្ធនឹងនៅក្បែរជើងភ្នំនឹង។

ក៖ ចាស!ហើយអ៊ីមានទីលំនៅ នៅឯណាដែល?

ខ៖
ខ្ញុំកាលមុននៅកាលពីសង្គមនឹងខ្ញុំមានទីលំនៅកាលដែលគេបានជំលាស់មកពីអាពតនឹងខ្ញុំមានទីលំនៅខាងមុខពេទ្យរ៉ុស៊ីយើងនឹងនៅចំរើនផលយើងនឹងដល់ពេលដែលប្តីខ្ញុំ...។

ក៖ នៅទីក្រុងភ្នំពេញយើងនឹង?

ខ៖
ចាស!តែដ៏ពេលប្តីខ្ញុំនឹងវាឈឺចឹងទៅយើងនឹងក៏បានទៅនៅភ្នំពិសិទ្ធិនៅភូមិស្រែអំបិលគេនឹងស្រែអំបិល ស្វាំងគេនឹង ស្រុកពញ្ញាលឺគេនឹងខ្ញុំបានទៅនៅនឹង។

ក៖ ចាស!ក្រោយមកសព្វថ្ងៃនឹងអ៊ីមានទីលំនៅនៅឯណាដែល?

ខ៖ នៅនឹងតែម្តងអូននឹងនៅស្រុកពញ្ញាលឺ
ឃុំស្វាំងគេនឹងខេត្តកណ្តាលគេនឹងដែលយើងបានទៅនៅឯជើងភ្នំនឹង។

ក៖ ចាស!ចឹងអ៊ីមិនភ្លាប់បានផ្លាស់ទីលំនៅទៅនៅឯណាផ្សេងទេ?

ខ៖ ខ្ញុំបានផ្លាស់ទៅទេ ខ្ញុំបបានផ្លាស់ទៅលំនៅទៅនៅពីភ្នំពេញនឹងទៅនឹងតែម្តង។

ក៖ ចាស!ចឹងដីនឹងជាកម្មសិទ្ធរបស់អ៊ីតែម្តង?

ខ៖ ចាសកម្មសិទ្ធដែលបាន ឪពុកក្មេកគាត់ខ្ញុំនឹងគាត់បានចែកអោយតែម្តង
ខ្ញុំគ្មានទេទៅខ្លួនទទេទេ
រកហូបដូចថាខ្ញុំរកពីបាទដៃទទេរចឹងទៅទិញដីនៅឯភ្នំពេញយើងនឹងបាន៨០០ទៅ៥០០តែដល់ពេលដែលប្តីយើងនឹងវាបានធ្លាក់ខ្លួនឈឺទៅជាជំងឺលើសឈាមនោះ
ចឹងក៏ខ្ញុំនឹងបានលក់ដីនឹងចំនួន២០០០$សំរាប់ទៅមើលគាត់នឹងពេលនឹងនោះសំរាប់ទៅមើលជំងឺរបស់គាត់ដល់ពេលដែលមើលហើយនឹងបានទៅនៅឯស្រែនឹងពេលនឹងប្តីខ្ញុំនឹងឪពុកគាត់

បានចែកដីអោយដីក្បាល២០បណ្តោយ៤៥ ហើយបានចែកដីនឹងទៅអោយកូនអីនឹងទៅនៅបន្តទៀតនឹងទៅ។

កៈ ចាស !អូ !ហើយឪពុកម្តាយរបស់អ៊ីនឹងគាត់មានឈ្មោះអ្វីដែល?

កៈ និយាយទៅឪពុកខ្ញុំនឹងគាត់ឈ្មោះអ៊ុកសំអឿ តែគាត់អត់នៅផងគាត់បានស្លាប់បាត់ទៅហើយតែចំណែកឯម្តាយខ្ញុំវិញគាត់មានឈ្មោះថាជា ថុល។

កៈ ចាស! ចុះខាង លោកពូវិញដែលត្រូវជាស្វាមីរបស់អ៊ីវិញតើឪពុកម្តាយរបស់គាត់មានឈ្មោះអ្វីដែរ?

ខៈ ឪពុករបស់គាត់មានឈ្មោះថា ភិន ម្តាយគាត់គឺយាយលុងមាលីសនោះ។

កៈ ចាស!ចឹង ស្វាមីរបស់អ៊ីគាត់មានឈ្មោះអ្វីដែល?

ខៈ គាត់មានឈ្មោះថា ភិនសុខុម។

កៈ ចាស!ហើយគាត់មានទីលំនៅស្រុកកំណើតរបស់គាត់ឯណាដែល?

ខៈ គាត់មានទីលំនៅនៅភូមិស្រែអំបិលនឹង ឃុំស្វាំងនឹង ស្រុកពញ្ញាលឺនឹង នឹងគឺជាស្រុកកំណើតរបស់គាត់។

កៈ ចាស!ចឹងចុះកាលនឹងតើអ៊ីមានបានចាំថាកាលនឹងអ៊ីហើយនឹងលោកពូបានស្រលាញ់គ្នាឬក៏ឪពុកម្តាយជាអ្នករៀបឬទុកដាក់អោយ?

ខៈ ការនឹងបានស្រលាញ់គ្នាដោយចិត្តឯងៗហើយពេលនឹងប្តីខ្ញុំនឹងបានស្រលាញ់គ្នាដោយចិត្តឯងចឹងដល់ពេលដែលរៀបក៏ម្តាយឪពុកមិនដឹងព្រោះកាលនឹងរៀបនឹងអត់មាន មេក្រូអីទេកាលនឹងនោះគឺគេចង់តែអង្គហាហ៎។

កៈ ចឹង...

ខ៖
មានន័យថាកាលនឹងគាត់បានស្រលាញ់យើងនឹងដោយចិត្តឯងគាត់មិនបានអោយម្តាយគាត់នឹងបានដឹងទេដល់ពេលដែលយើងរៀបហើយនឹងបានជាគាត់បានអោយម្តាយឪគាត់បានដឹងដែរ។

ក៖ ហឺ!ចឹងកាលនឹងអ៊ីអត់បានរៀបអាពាហ៍ពិពាហ៍ទេកាលនឹងគ្រាន់តែសែនអី?

ខ៖ កាលនឹងបានការតើតែពេលជំនាន់នឹងយើងមិនទាន់មានមេក្រូគេចង់អង្គ។

ក៖ កាលនៅ នៅជំនាន់ឆ្នាំណាដែលអ៊ីបានការ?

ខ៖ ខ្ញុំដូចជាអត់បានចាំទេកាលនឹងនោះព្រោះអីគេមិនទាន់នឹងចាយលុយផងនឹងកាលនឹង។

ក៖ កាលនឹងមុខសម័យអាពតឬក៏ក្រោយអាពត?

ខ៖ ពេលដែលបានជំលៀសអាពតហើយនឹងបានមកនៅនឹងជិតពេទ្យរ៉ុសស៊ីនឹងនោះ។

ក៖ ចាស!ចឹងកាលនឹងអ៊ីបានស្រលាញ់គ្នានឹងបានយូរដែលហើយន៎?

ខ៖ ចាស!!!

ក៖ បានប៉ុន្មានឆ្នាំដែរហើយអ៊ី?

ខ៖ មើលឡើងខ្ញុំនឹងមានមីងបងនឹងអាយុ៣០ឆ្នាំហើយនឹង។

ក៖ អូ!ចឹងប្រហែលជា៥០អីហើយចឹង?

ខ៖ ចាស!!!

ក៖ ចឹងលោកពូវិញមានអាយុប៉ុន្មានឆ្នាំដែល?

ខ៖ ប្តីរបស់ខ្ញុំនឹងគាត់មានអាយុ៥៥ឆ្នាំ ៥៦ឆ្នាំហើយ។

ក៖ សព្វថ្ងៃនេះ?

ខ៖ ចាស!!!

កៈ ចាស!ហើយគាត់ឥឡូវនឹងគាត់នៅតែជាមួយនឹងអីនៅជាមួយនឹងគ្នារហូត?

ខៈ ចាស!!គាត់នៅជាមួយនឹងខ្ញុំនឹងសព្វថ្ងៃ។

កៈ ចាស!!គាត់មានមុខរបរជាអ្វីដែរ?

ខៈប្តីខ្ញុំនឹងគាត់ឡើងត្នោតហើយកាលពីមុននឹងគាត់បានធ្វើជាទាហ៊ានកាលនឹងគាត់បានធ្វើទាហានជាមួយនឹងលោកហ៊ុនសែនកាលនឹងតែគ្មានទីលំនៅទេទៅធ្វើនឹង
មិនបានផលអីនឹងគេផងហ៎។

កៈ គាត់ជាអង់ការៈលោកតា សែន?

ខៈ
គាត់បានធ្វើជាទាហ៊ាននឹងគេនឹងជាមួយនឹងលោកហ៊ុនសែននឹងទៅដល់ភ្នំស្រួចអីនឹងកាលនឹងហើយកាលនឹងខ្ញុំនឹងនេស
ពេលដែលគាត់បានចូលធ្វើជាទាហាននឹងខ្ញុំបានមានកូន២នាក់មានកូនប្រុសអាបងគេនឹង២នាក់នឹងហើយដល់ ពេលគាត់បានមកវិញអត់មានដីឯណានៅ។

កៈ ហឺ!!!

ខៈ ព្រោះពេលនឹងគេមិនបានទៅផ្គុតផ្គង់អីទៅអោយយើងកាលនឹងយើងនៅជាទាហាននឹង។

កៈ
ចុះកាលនឹងពេលដែលលោកពូបានធ្វើជាទាហាននឹងគាត់មានប្រាក់ដើម្បីនឹងចិញ្ចឹមភ្ញើរមកអោយអីជារៀងរាល់ខែឬទេ?

ខៈ
ហឺ!កាលនឹងគាត់ហូបតែខ្លួនគាត់ទេគាត់មិនបានទៅចិញ្ចឹមខ្ញុំនោះទេកាលនឹងគាត់បានបើកប្រាក់ខែមកសំរាប់ទាហាននឹងហើយគាត់បាននាំគ្នាទៅផឹងស៊ីសំរាប់ពួកទាហានៗគ្នាគាត់នឹងសំរាប់ពួកទាហានៗគ្នាឯងនឹង។

កៈ គាត់មិនបានផ្តល់ប្រាក់អោយសំរាប់ក្រុមគ្រួសារឬក៏កូនអីទេ?

ខៈ អត់មានទេ។

កៈ ចឹងពេលនឹងអី មីងធ្វើយ៉ាងណាដើម្បីចិញ្ចឹមកូននឹងខ្លួនឯងបាន?

ខៈ ខ្ញុំកាលនឹង
ដូចថាពេលដែលយើងនឹងចិញ្ចឹមកូនពេលមួយហឹកនឹងខ្ញុំបានអត់ចឹងខ្ញុំក៏ទៅកាត់អីដូចជាកាផ្លោកដើម្បីនឹងសំរាប់ធ្វើចំណងសំរាប់នឹងលក់កាលនឹងនោះ។

កៈ ចាស!!!

ខៈ អាយើងទៅជៀលកាផ្លោកនឹងមក

កៈ ចាស!ខ្ញុំបានភ្លាប់បានឃើញវាស្អាត។

ខៈ នឹងយើងអាជៀលវាដើម្បីនឹងយកលុយមកចិញ្ចឹមកូនតើកាលនឹងតើទំរាំតែបាន។

កៈ ហើយកាលនឹងអីអាចរកបានប៉ុន្មានទៅកាផ្លោកនឹង?

ខៈ
កាលនឹងលក់មួយសានឹងដូចជាបានប៉ុន្មានកាក់ទេកាលនឹងទំរាំតែបានមកវាវេទនាសឹកតែងាប់ហើយកាលនឹងខ្ញុំតែប៉ុណ្ណឹងឥឡូវខ្ញុំថាខ្ញុំបានរៀងធូហើយ។

កៈ កាលនឹងអីទៅកាត់ដើមកំផ្លោកនឹងនៅ នៅឯណាដែលអី?

ខៈ នៅឯពេទ្យរ៉ុសស៊ីយើងនឹងនៅអាកន្លែងស្ទឹងនឹង
អាកន្លែងមានបន្លាយដែលគេមិនទាន់បានចាក់នឹងវាមិនមានកំផ្លោកតែឥឡូវគេបានចាក់។

កៈ បន្លាយឡូមែនអី?

ខៈ នឹងហើយអាបន្លាយឡូគេនឹងបន្លាយកន្លែងពេទ្យរ៉ុសស៊ីយើងនឹងវាមានកំផ្លោក។

កៈ ចាស!នឹងហើយ

ខៈ នឹងហើយពេលនឹងនាំគ្នាទៅធ្វើជាក្បូនសំរាប់ទៅកាត់កំផ្លោកនឹង។

កៈ ចាស!ហើយចំណងនឹងក្នុង១ថ្ងៃនឹងចឹងអីអាចរកចំណូលបានប៉ុន្មានដែរ?

ខ៖
អានឹងយើងពិបាកនិយាយណាស់ជួនកាលទៅក្នុង១ថ្ងៃអីនឹងបានតែ២០០០រទៅ៣០០០រអីចឹងទេកាលនឹងនោះព្រោះអីកាលនឹងប្តីខ្ញុំនឹងគាត់ឈប់ធ្វើជាទាហានចឹងទៅគាត់ទៅរត់ធ្វើជាអ្នករត់ស៊ីខ្លួលវិញហើយពេលនឹងស្អីក៏គាត់ធ្វើដែលប្តីខ្ញុំនោះ...

ក៖ ចាស!!!

ខ៖
គាត់មិនទៅប្រកាន់វណ្ណៈនោះទេគាត់ទៅរត់ស៊ីឃ្លួទំរាំបានចិញ្ចឹមបានកូន៨នាក់នឹងវាវេទនាបំផុតអត់មានថាទៅពឹងម្តាយឪទេបើថាគាត់ទៅធ្វើជាទាហាននឹងគាត់បានចាញ់មួយដងអីចឹងហើយដល់ពេលដែលយើងនឹងធ្វើកំផ្លោកនឹងវារកហូបអីវាមិនទាន់ហ៎...

ក៖ ចាស!!!

ខ៖
ដល់ហើយទៅឪពុកក្មេកខ្ញុំនឹងគាត់បានយកលុយទៅអោយដល់ផ្ទះឯណោះអានឹងប្តីខ្ញុំពេលនឹងខ្ញុំស្មានតែងាប់ហើយតើព្រោះអីពេលនឹងគាត់ចាញ់នោះពេលនឹងគឺគាត់កំពុងតែធ្វើជាទាហាននោះ។

ក៖ ចាស!!!

ខ៖ នឹងហើយ

ក៖ ចាស!ត្រូវហើយគាត់លះបង់ខ្ពស់ណាស់ព្រោះគាត់ធ្វើជាទាហាន។

ខ៖ មេគាត់នឹងនៅស្គាល់គាត់តើតាដួង
ចោមអីគេនឹងគាត់រកតើតែពេលដែលគាត់នឹងបានឈប់នឹងទៅយើងនឹងស្អីក៏យើងមិនបាននឹងគេដែល។

ក៖ ហឺ!! ចុះកាលនឹងមូលហេតុអ្វីបានជាលោកពូគាត់បានឈប់ពីការងារទាហាននឹង?

ខ៖
ព្រោះកាលនឹងគាត់បានមើលមកប្រពន្ធកូនវាវេទនាដល់ហើយទៅពេលនឹងមេគាត់បានហៅ

គាត់ទៅវិញតើមេគាត់បានទៅថា អើអាខុមអីទៅកែន
ហើយពេលនឹងខ្ញុំនឹងបានដឹងដែលនោះថាមើល អើឯងអា គេប្រមូលទ័ពទៅព្រៃហើយ
ដល់ពេលហើយគាត់បានមើលឃើញកូនវានៅវេទនានោះវាអត់មានអីសំរាប់ហូបនោះដល់ពេ
លហើយទៅប្តីខ្ញុំនឹងគាត់បានប្រាប់មេនឹងថាបងឯងទៅមុនទៅតិចទៀតខ្ញុំទៅហើយ
ដល់ពេលហើយប្តីខ្ញុំនឹងគាត់មានបានទៅឯណាគេក៏បានប្រមូលទ័ពទៅបាត់ទៅនឹង
ហើយដល់ចឹងទៅបានជាគាត់នៅរស់ដល់ឥឡូវនឹង
គាត់អត់ទៅព្រោះកាលនឹងគាត់បានឃើញថាយើងនឹងវានៅវេទនានោះ។

ក៖ ចឹងកាលនឹងគេបានប្រមូលទ័ពដើម្បីនឹងយកទៅហាតឬក៏យកទៅ?

ខ៖ កាលនឹងគេទៅហាត់ហើយឡើងវៃតែម្តង គេអោយគាត់ទៅឡើងវៃ។

ក៖ អូ!កាលដែលគេឡើងវៃគ្នានៅឯភ្នំពេញនឹងហ៎?

ខ៖ នឹងហើយ កាលនឹងគេបាននាំទៅវៃគ្នាមិនដូចជាជំនាន់យើងទេដែលបានស្រួលនោះ
កាលនឹងគេវៃណាស់ដូចជាមិត្តភក្តិគាត់នឹងកាលនឹងគេដាច់ជើងហើយខ្លះស្លាប់តែគាត់នឹងមិន
អីព្រោះពេលដែលគេបានមកហៅគាត់នឹងគាត់មិនបានទៅគេបានប្រមូលទព័ទៅនឹងគាត់អត់
ទៅ ប៉ុន្តែពេលដែលធ្វើនៅយើងនឹងវាវេទនាព្រោះមិនដឹងជានឹងរកអីគេហើយមានកូនហ៎
តែសំរាប់ខ្ញុំនឹងវាមិនបានទៅពឹងនរណានោះទេខ្ញុំទៅរក២នាក់ប្តីប្រពន្ធខ្ញុំនឹងកូនខ្ញុំ។

ក៖
ចាស!ហើយឥឡូវនឹងតើគាត់នៅតែមានទំនាក់ទំនងខាងមេគាត់នៅពេលដែលជាទាហានទៀ
តដែលឬទេ?

ខ៖ គាត់មិនដែលបានទាក់ទងនោះទេ។

ក៖ គឺបានដាច់តែម្តង?

ខ៖ ចាស!បានដាច់តែម្តង។

ក៖

ចាស!ហើយពេលដែលគាត់បានសំរាច់ចិត្តធ្វើជាទាហាននឹងតើអីបានដឹងដែរឬទេថាគាត់ជាទាហាន?

ខ៖

កាលនឹងគាត់បានធ្វើជាទាហាននឹងកាលនឹងគេបានរើសគាត់អោយចូលដល់ពេលហើយនឹងបានជាគាត់បានធ្វើនឹងចូលធ្វើតែម្តងទៅខ្ជិលអោយគេចាប់ចូល។

ក៖

ប៉ុន្តែពេលនឹងខ្ញុំបានលឺគេថាកាលនឹងពេលដែលយើងមានគ្រួសារគេមិនអោយយើងនឹងចូលទេតែបើថាយើងនឹងនៅលីវបានជាគេអោយយើងនឹងចូល។

ខ៖ កាលនឹងមានគ្រួសារក៏គេអោយចូលដែលគេដើរហៅអោយចូល។

ក៖ អូ!កាលនឹងគេមិនបានចាប់យើងទេតែគេហៅយើងចូលតែម្តង?

ខ៖ ចាស!យើងចូលទៅតែម្តងព្រោះយើងមិនចង់អោយគេចាប់ចឹងយើងទៅចូលតែម្តង។

ក៖ គេចាប់នឹងគេបានបង្ខំយើងន៎គេគេអោយយើងនឹងត្រូវតែចូល?

ខ៖

អត់ទេគេមិនបានបង្ខំយើងទេគេគ្រាន់តែសួរយើងចឹងទៅថាយើងនឹងចង់បំរើជាតិអីចឹងទៅណា។

ក៖ ចាសៗ

ខ៖ ចឹងបើយើងនឹងចង់បំរើជាតិអីនឹងយើងក៏ចូលទៅ។

ក៖ ហឺ!! ចាស!!ត្រូវហើយពេលនឹងគាត់បានលះបង់ខ្លង់មែនទែនចាស។

ខ៖ ចាស!!!

កៈ
ហើយអីសព្វថ្ងៃដូចថាអ៊ីដូចថាសព្វថ្ងៃនឹងអ៊ីមានការលំបាកអីគេដែលអ៊ីឆ្លងកាត់មកហើយនឹងចាំជាង?

ខៈ
ខ្ញុំពិបាកជាគេហើយខ្ញុំនឹងចាំជាងគេមួយហ៊ឹកជំនាន់នឹងវាពិបាករឿងហូបចុកពេលនឹងកូនរបស់ខ្ញុំនឹងពេលដែលវាបានទៅរៀនហើយដើររើសអេបចាយយកមកដើរទិញអង្ករហូប
ពេលនឹងយើងដើររើសអេបចាយយកមកដើម្បីនឹងទិញអង្កមកហូបម្តងៗនឹងវាវេទនាណាស់ជីវិតអ្នកក្រវាចឹងចឹងបានថាពេលដែលគេអត់ដូចជាអ្នករើសអេបចាយចឹងខ្ញុំមិនបានទៅមើលងាយគេទេអ្នកខ្លះមើលងាយគ្នា
ខ្ញុំមិនទៅមើលងាយគ្នានោះទេព្រោះអីខ្ញុំបានហែរឡើងឆ្អែកហើយដើររើសអេបចាយឡើងឆ្អែកហើយនៅកន្លែងចាក់សំរាមនឹងចេះតែស៊ូ ទើបតែឥឡូវទេ
តែទោះបីជាយ៉ាងណាឥឡូវបើខ្ញុំឃើញអែប ចាយក៏ខ្ញុំនៅតែរើស។

កៈ ចាស!!!

ខៈ
ព្រោះអានឹងមិនមែនយើងលួចគេទេអានឹងរបស់វាមិនមែនថោកទេព្រោះអីខ្ញុំមានប្រវត្តិខ្ញុំជាអ្នកក្រ។

កៈ ចាស!!យើងអាចរកបានមកតក់មកសន្សំ។

ខៈ ចាស!!!

កៈ ចាស!ហើយចឹងកាលនឹងអ៊ីរើសអែបចាយនឹងធ្វើការពីម៉ោងណាដល់ម៉ោងណាដែល?

ខៈ កាលនឹងខ្ញុំរើសពេលយប់ចាប់ពីម៉ោង៩ព្រឹកនឹងខ្ញុំបានងើបទៅហើយ
ហើយបានខ្ញុំរើសហើយយកទៅលក់បន្ទប់មកបានជាខ្ញុំនឹងទៅសំរានហើយដល់ពេលដែលដល់ម៉ោង៤នឹងខ្ញុំងើបទៅទៀតហើយ
ហើយពេលខ្លះនឹងដល់ពេលម៉ោង៥អីនឹងខ្ញុំទៅទៀតព្រោះអីយើងត្រូវតែទិញសំរាមនឹងពីឡាន

ហើយអាមួយហឹកនឹងខ្ញុំបានទៅរើសនៅកន្លែងដែលគេបានចាក់ជាគំនរសំរាមដែលឡានគេទៅចាក់នោះ។

ក៖ ចាស!!!

ខ៖
ដល់ពេលដែលគេទៅចាក់នឹងគេលក់១ឡានដូចជា៥០០០រហើយពេលនឹងយើងទិញចឹងទៅគេក៏បានចាក់មកអោយយើងនឹងរើសហើយ។

ក៖ អូ!កាលនឹងយើងទិញចឹងទេនោះ។

ខ៖ ចាស!!!

ក៖ កាលនឹងយើងទៅរើសនៅគុំនរសំរាមនៅស្ទឹងមានជ័យនឹងមែន?

ខ៖ ចឹងហើយនៅស្ទឹងមានជ័យនឹង ខ្ញុំនៅជិតនឹងតើមុននឹង។

ក៖ ចាស!ហើយការងារនឹងក្នុង១ថ្ងៃអ៊ីអាចរកបានប្រាក់ប៉ុន្មានដែរក្នុង១ថ្ងៃ?

ខ៖ អូ!កាលនឹងវារកមិនបានច្រើនប៉ុន្មានដែលបានតែ៦០០០០រទៅ៧០០០០រ
យកមកបែកចែកទិញស្ករម្ហូបអីចឹងទៅពេលនឹងដូចថាវាម៉ាគ្រាប់ម៉ាគ្រាន់ចឹងទៅណា។

ក៖ ចាស!!!

ខ៖ ហើយដល់ពេលដែលយើងនឹងឈឺបានជាវាខ្វះខាត
យើងរកមិនគ្រាប់បានតែមួយហូបៗទេព្រោះអីយើងនឹងវាកូនច្រើន។

ក៖
ចាស!!ត្រូវហើយចឹងនេះគឺជាការងារដែលអ៊ីបានធ្វើបន្ទាប់ពីបានរៀបការជាមួយនឹងលោកពូហើយទើបតែបានដាច់អាពត។

ខ៖ ចាស!!

ក៖ ហើយចុះអ៊ីមានបងប្អូនដែលបានស្លាប់នៅក្នុងជំនាន់អាពតដែលឬទេ?

ខ៖
មានតើកាលនឹងមានបងជីដូងមួយខ្ញុំនឹងបានស្លាប់នៅក្នុងជំនាន់ពពតស្លាប់នៅជំនាន់ពពតហើយពេលនឹងខ្ញុំនឹងនៅតូចដល់ពេលចឹងទៅខ្ញុំនឹងមិនបានដឹងទេ
ពេលនឹងគាត់បានអោយខ្ញុំនឹងទៅដាស់បងខ្ញុំនឹងអោយហូបបបរតែដល់ពេលដែលខ្ញុំនឹងទៅដាស់បងខ្ញុំថាបងៗហ៊ាមៗបងឯងងើបឡើងមកញ៉ាំបបរ
ពេលនឹងដាស់គាត់ហើយនឹងមិនងើបហើយពេលនឹងខ្ញុំនឹងក៏បានទៅហៅឪពុកខ្ញុំប៉ាខ្ញុំបានហៅបងគាត់មិនបានងើបនោះទេ។ ហើយចឹងកូនឯងមិនទៅដាស់វាហើយទាញវាមើលកូន ហើយពេលដែលខ្ញុំទៅដាស់គាត់ហើយទាញគាត់មកនឹងបងខ្ញុំនឹងគាត់បានស្លាប់បាត់ហើយ ចឹងទៅប៉ាខ្ញុំនឹងក៏យកគាត់ទៅកប់ទៅ។ ខ្ញុំបានបែកបាក់បងខ្ញុំ មានបង៣ បងហាម បងខ្ញុំបារាំង កាលនៅជំនាន់អាពតនឹងខ្ញុំបានបាត់បងខ្ញុំម្នាក់ទៀតកាលបឹងបងបារាំងដែលបានស្លាប់ទៅនឹង
...

ក៖ ចាស!!

ខ៖
ពេលនឹងមិនបានដឹងថាគាត់ទៅណាព្រោះកាលនឹងពេលដែលខ្ញុំបានជំលៀសមកនឹងខ្ញុំបានមកនេះតែម្តងខ្ញុំមិនបាននៅស្រុកកំណើតនោះទេ
ស្រុកកំណើតរបស់ម្តាយខ្ញុំនឹងគាត់នៅស្រុកសំរងតងយើងនឹង។

ក៖ ចាស!!

ខ៖ ដល់ពេលហើយទៅគេជំលៀសគាត់ទៅនៅបងខ្ញុំនឹងគាត់បានមករកដែរឬអត់?

ក៖ កាលនឹងបងទាំង២នាក់នឹងគាត់ជាប្រុសទាំង២នាក់?

ខ៖ ចាស!!

ក៖ តើកាលនឹងគាត់មានអាយុប៉ុន្មានដែរ?

ខ៖ កាលនឹងខ្ញុំមិនសូវជាចាំប៉ុន្មាននោះទេកាលនឹងគាត់ដូចជាមានអាយុ១៥ទៅ១៦ឆ្នាំ ១០ទៅ២០ ហើយ១៦ទៅ១៧អីចឹងទៅណាខ្ញុំមិនបានចាំទេ
ហើយតើពេលដែលគាត់នេះចឹងគាត់ដើរមកលេងនឹងខ្ញុំហើយពេលដែលគាត់នឹងខ្ញុំចឹង

ព្រោះពេលនឹងគាត់នៅមានខ្ញុំហើយមានបងប្អូន២នាក់ទៀតតែគាត់បានបែកគ្នាជាមួយនឹងមិត្តអស់ទៅហើយបងខ្ញុំនឹងគាត់មានប្រជ្រុយពេញខ្លួន។

ក៖ ហឺចាស!!

ខ៖
ហើយដល់ពេលឥឡូវនឹងមិនដឹងជាយ៉ាងម៉េចទេគាត់បានបាត់ដល់ឥឡូវនឹងរហូតទៅមិនដឹងជាយ៉ាងម៉េចនោះទេ មិនដឹងថាគាត់យ៉ាងម៉េចនោះទៅឥឡូវនឹង។

ក៖ បាត់ដំណឹងគាត់តែម្តង?

ខ៖ ចាស!!!

ក៖
ចុះអ៊ីមានបានផ្សាយតាមទូរស្សន៍អ្វីដើម្បីនឹងស្វែងរកគាត់ដែលឬទេ?ដើម្បីរកសាច់ញ្ញាតិដែរឬទេ?

ខ៖
អត់ទេពេលនឹងខ្ញុំនៅក្មេងៗចឹងខ្ញុំមិនសូវជាបានដឹងនោះទេព្រោះអីកាលនឹងប៉ារបស់ខ្ញុំគាត់មិនបានប្រាប់ព្រោះគាត់បានស្លាប់បាត់ទៅហើយ។

ក៖ ចុះអ៊ីចង់ប្រកាសដើម្បីស្វែងរកគាត់ដែលឬទេ?

ខ៖ មិនដឹងត្រូវប្រកាសថាយ៉ាងម៉េច?រកយ៉ាងម៉េចទៀត?

ក៖ ដំណឹងស្វែងរកបងប្អូនដែលបានបាត់កាលពីជំនាន់អាពតដែលមានផិនភាក់សណ្ឋានមានរូបថតគាត់ដែលឬទេអ៊ី?

ខ៖ អត់ អត់អាលីងតាម៉ងកាលជំនាន់នឹងនោះ។

ក៖ ចុះមានបានចាំផិនភាក់របស់គាត់ដែលឬទេ?

ខ៖ ខ្ញុំមិនបានចាំទេកាលនឹងនោះព្រោះអីខ្ញុំនៅតូច។

ក៖ ចុះអ៊ីមានបានចាំឈ្មោះរបស់គាត់ទេ?

ខ៖ ខ្ញុំបានចាំតែបងខ្ញុំមួយនឹងគាត់ មើលបងអីដែលគាត់មានប្រជ្រុយពេញខ្លួននឹងគាត់ដូចជាមានឈ្មោះថាបងបារាំង ឈ្មោះបងបារាំងហើយមើលមានបងមួយទៀតឈ្មោះអី...មើលនឹងហើយមានបងមួយទៀតនឹងគាត់ឈ្មោះបងពាលទេនឹងហើយបងបារាំងនឹងគេដាក់ឈ្មោះអោយគាត់គឺឈ្មោះបងពាលទេ ចឹងគេហៅគាត់ថាពពាលចឹងណាព្រោះអីគាត់មានប្រជ្រុយពេញខ្លួនចឹង ហើយមួយទៀតនឹងគាត់មានឈ្មោះថាបងបារាំងទេមានបងប្អូនពនាក់ បាត់បងម្នាក់នឹងឡើងស្ងត់ឆឹង។

ក៖ ហឺ!!

ខ៖ ខ្ញុំមិនបានដឹងពីគាត់ដែរ។

ក៖ ចឹងបងម្នាក់គាត់ឈ្មោះបងហាមនឹងគាត់បានស្លាប់ដោយសារជំងឺអ្វីដែរ?

ខ៖ កាលជំនាន់ពពតនឹងគាត់កើតអាស្មីដូចជាជំបៅងារនោះ មានដង្កូវឡើងណែន ប៉ារបស់ខ្ញុំនឹងគាត់បានមើលដែលនឹងតែមិនបានដឹងថាមូលហេតុអ្វីបានជាគាត់នៅតែស្លាប់ទៀត កាលនឹងខ្ញុំវានៅតូចៗដែលចឹងខ្ញុំមិនសូវជាបានដឹងនោះទេ ពេលនឹងខ្ញុំបានយកបបរយកអោយគាត់ហូបហើយមិនបានដឹងថាគាត់ស្លាប់ផងអត់បានដឹងផងនឹង។

ក៖ អើ ជំងឺពពាល..

ខ៖ កាលនៅជំនាន់នឹងគេរកតែសំលាប់ខ្ញុំប៉ុន្នានដងហើយនឹង។

ក៖ ម៉េចបានចឹងអី?

ខ៖ វាថាកាលនឹងយើងនឹងបានលេងប៉េលុកប៉េឡចឹងហើយបានជាគេថាព្រោះអីកាលនឹងក្មេងៗនឹងគេមិនបានអោយលេងទេ ហើយគេថាយើងនឹងស៊្មីៗចឹងទៅគេនឹងក៏បានចាប់យើងនឹងទៅចង់ទៅ ហើយបងខ្ញុំបានមានបងហាមនឹងបងបារាំងនឹងដែលខ្ញុំបាននិយាយនឹងគាត់បានទៅប្រាប់ប៉ាខ្ញុំបានពួៗគេចាប់មីងអូនហើយ ចឹងទៅប៉ាខ្ញុំនឹងទៅសួរថាមិត្តៗកូនខ្ញុំនឹងវាធ្វើអ្វីខុស?

គេប្រាប់ទៅហើយប៉ាខ្ញុំនឹងបានប្រាប់គេថាដោយសារកូនរបស់ខ្ញុំនឹងគេនៅក្មេងចឹងហើយវាមិនបានជាដឹងអី
ចឹងហើយគេក៏បានលែងខ្ញុំនឹងវិញទៅចឹងហើយបានជាខ្ញុំនឹងបានរស់ទៅកុំអីខ្ញុំប្រហែលជាស្លាប់នៅក្នុងជំនាន់អាពតនឹងបាត់ហើយមើលទៅនោះដែរនោះមើលទៅ
ចេះបានឆ្លងផុតមកដល់ឥឡូវនេះ។

ក៖ ចុះប៉ុន្មានដងហើយដែលគេបានចាប់អី?

ខ៖ គេចាប់ខ្ញុំបានម្តងទៀតនឹងគេថាខ្ញុំនឹងជាក្មួយរបស់ឪសារ៉េត។

ក៖ ហាហាហា

ខ៖ ហឺស! គេថាបើចង់ឃើញឪសារ៉េតអោយមើលតែមុខរបស់២នាក់នឹងទៅនឹងហើយ
ចឹងគេដ៏បានចាប់ខ្ញុំមកម្តងទៀតទៅ
ហើយអាបងរបស់ខ្ញុំនឹងគាត់ក៏បានទៅប្រាប់ប៉ារបស់ខ្ញុំទៀតហើយ ពូៗន៎
គេបានចាប់មីអូនទៀតហើយ។ គេចាប់រឿងអីហាហ៎ គេថាមីអូននឹងក្មួយឪសារ៉េត
ចឹងប៉ាខ្ញុំនឹងក៏ទៅសួរគេថាមិត្តកូនរបស់ខ្ញុំនឹងវាខុសអីបានជាចាប់កូនរបស់ខ្ញុំចង់
អីគេបានប្រាប់ខ្ញុំថានឹងវាជាក្មួយរបស់ឪសារ៉េតហើយប៉ារបស់ខ្ញុំថាហើយមិត្តអើយខ្ញុំមិនបានដឹងថាឪសារ៉េតនឹងបែរមុខទៅណាទេ
ចឹងហើយបានជាគេនឹងបានដោះលែងខ្ញុំមកវិញកុំអីខ្ញុំងាប់នៅក្នុងជំនាន់នឹងបាត់ទៅហើយមិនបានមកជួបនៅក្នុងជំនាន់នឹងនោះទេមិនបានមានកូននោះអីទេហ៎។

ក៖ ចាស!! ហើយនៅមួយដងទៀតវាមាន៣ដងត្រូវទេអី?

ខ៖ ចុះក្រោយនឹងមានអីពេលនឹងបានពេលដែលគេនឹងជំលៀសមកនៅជាមួយនឹងម្តាយ។

ក៖ ចាស!! ហើយកាលនឹងគេបានជំលៀសអីមកវិញនឹងនៅឯណាដែរ?

ខ៖ កាលនឹងខ្ញុំនៅឯបាត់ដំបង។

ក៖ ចុះអីមានបាននៅចាំកន្លែងដែលឬទេ?

ខ៖ អីកាលនឹងនៅឯជើងភ្នំ។

កៈ នៅឯជើងភ្នំបាត់ដំបងនឹង?

ខៈ ចាស!នៅឯភ្នំ។

កៈ គេហៅថាជាភ្នំអ្វីដែល?

ខៈ គេហៅថាជើងភ្នំបាក់ដេនឹងហើយ។

កៈ ចាស!!!

ខៈ នៅឯជើងភ្នំ។

កៈ ហើយកាលនឹងគេបានប្រើអីអោយធ្វើអ្វីខ្លះ?

ខៈ យើងកុមារគេប្រើអោយយើងនឹងកាប់ជី
ចិញ្ចាំងគេប្រើអោយយើងនឹងចិញ្ចាំងអាជីកន្តៀងខេតន៎គេបានកាប់ជីកាប់អីនឹងទៅចិញ្ចាំងទៅ
ដាក់នៅក្នុងស្រែ។

កៈ ចាស!!!

ខៈ នឹងហើយគេបានប្រើអោយចិញ្ចាំងជី។

កៈ ចឹងគេបានប្រើអោយអីចិញ្ចាំងតែប៉ុណ្ណឹងនោះទេ?

ខៈ នឹងហើយ ខ្ញុំដើរស្ទូងទៀតនឹងកាលជំនាន់អាពតនឹងនោះ
ហើយដល់ប៉ារបស់ខ្ញុំគាត់បានប្រាប់គេថាកូនរបស់ខ្ញុំនឹងវានៅក្មេងនឹងហើយប្រើវាស្ទុងស្រែដែរ
? ហើយគេថាហីប៉ុននឹងហើយនៅមិនទាន់ចេះស្ទូង?គេថាចឹងអោយប៉ារបស់ខ្ញុំនឹង
ចុះកាលនឹងគេបានយកយើងនឹងទៅស្ទូងពេលដែលយើងនឹងនៅតូចនៅឡើយ។
ហើយបើម្តាយគាត់បានឃើញកូនចឹងគាត់មានចិត្តអានិតចឹងណាព្រោះជាកូនរបស់ខ្លួន។

ក ៖ ហើយកាលនឹងគេបានអោយរបបអាហារវិញយ៉ាងម៉េចដែរ?

ខ៖
ហឺ!!របបនឹងអង្ក១វែកហើយខ្ញុំនិងអ្នកដែលមិនចេះហូបបបរនោះចឹងហើយបានជាពេលនឹងខ្ញុំ

ដងតែអង្គហើយសល់ទឹកប៉ុន្នានទុកអោយប៉ារបស់ខ្ញុំ
ខ្ញុំមិនដែលបានហូបទេតែពេលនឹងចេះអីនឹងនៅរស់ដែរ។

ក៖ ចាស!!អ៊ីហើយពេលនឹងអ៊ីមានធ្លាប់ឈឺអត់កាលនឹង?

ខ៖ អត់មានធ្លាប់បានឈឺនោះទេ។

ក៖ហើយកាលនៅជំនាន់អាពតនឹងអ៊ីបានចាំអីជាងគេដែលអ៊ីនឹងឃើញហើយនៅជាប់មកដល់ឥឡូវ?

ខ៖កាលនឹងចាំថាយើងនឹងវាវេទនាបែកបាក់ពីបងប្អូនចឹងទៅហើយគេប្រើយើងនៅពេលដែលយើងនឹងមិនទាន់បានគ្រាប់អាយុអីចឹង
គេអោយទៅណាក៏ត្រូវទៅកាលជំនាន់អាពតនឹងក្មេងក៏វាប្រើមិនដឹងអីនោះទេ។

ក៖ហើយពេលដែលបានដាច់មកនឹងអ៊ីបានជួបនឹងការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់អ៊ីរហូតដល់អ៊ីមានក្រុមគ្រួសារនឹងកូនរហូតមកដល់ឥឡូវនឹង?

ខ៖មានគ្រួសារចឹងទៅវានៅមានកាលលំបាកដូចជាយើងត្រូវចិញ្ចឹមកូនរបស់យើងដូចថាយើងត្រូវរើសអេបចាយដើម្បីនឹងចិញ្ចឹមកូនហើយឪពុកគាត់មានទៅរត់កង់មីដើម្បីយកលុយមកចិញ្ចឹមកូនចឹងទៅ។

ក៖ ហឺ!! ចាស!! ហើយអ៊ីមានធ្លាប់មានរឿងល្អនៅក្នុងជីវិតដែលឬទេ?

ខ៖
ពិបាកណាស់មិនដែលបានល្អនោះទេវាលំបាករហូតមកនឹង។(សំលេងភ្ញាក់ពេលដែលថៅយកស្បែកជើងកប់គ្នា ថាហែងឯងមិចបានជាយកស្បែកជើងទៅកប់បងចឹង?)

ក៖
ចាស!!អ៊ីចឹងពេលដែលបានដាច់អាពតមកនឹងអ៊ីមានរឿងអីពេលដែលអ៊ីនឹកឃើញហើយនឹងធ្វើអោយអ៊ីសប្បាយចិត្តដែលឬទេ?

ខ៖ សប្បាយចិត្តនឹងវាថាពេលដែលកូននឹងវារៀងគ្រាន់បើចឹងទៅយើងសប្បាយចិត្តព្រោះមានកូនចៅវាបានជួយជ្រុំជ្រែងចឹងទៅណាយើងជួបជុំគ្នាចឹងទៅ។

ក៖ ចាស!!ហើយចៅពេលដែលនៅក្មេងៗនឹងអ៊ីធ្លាប់ស្រមៃថាអ៊ីចង់ធ្វើជាអ្វីទេអ៊ី?

ខ៖ មិនធ្លាប់បានស្រមៃនោះទេពេលនឹងធ្លាប់បានស្រមៃថាចង់ធ្វើជាអ្នកដែលលេងល្ខោងដែរតែពេលនឹងប្រឡងវាមិនជាប់។កាលនឹងលេងល្ខោង។

ក៖ អូកាលនឹងលេងល្ខោងបាសាក់យើងនឹងអ៊ីហ៎?

ខ៖ ចាស!!!

ក៖ កាលនឹងគេសំភាសនដែរទេអ៊ី?

ខ៖ អត់ទេកាលនឹងគេគ្រាន់តែអោយយើងនឹងលេងអោយគេមើលល្ខោងនៅផ្សារដើមគយើងនឹងកាលនឹងផ្សារដើមគជាមួយនឹងលោកគ្រូសាន សុផាតនោះយើងនឹង។

ក៖ ចាស!!ចឹងកាលនឹងអ៊ីបានប្រឡងដែរ ប្រឡងអ៊ី..

ខ៖ ប្រឡងជាមួយនឹងលោកតាសេង កុងទៀត។

ក៖ ចាស!! ហើយបន្តមកអីដូចថាមាននៅក្នុងចិត្តនឹងអ៊ីមានបានចង់ធ្វើអ្វីទៀតដែរឬទេ?

ខ៖ ចង់ថាយើងលក់ដូរអីចឹងទៅប៉ុន្តែយើងវានៅខ្វះខាតចឹងទៅហើយយើងនឹងវាធ្វើអ្វីនៅមិនទាន់កើតចឹងទៅ។

ក៖ ហើយចឹងអ៊ីមានគំពោងអនាគតថានឹងចង់ធ្វើអ្វីដែរ?

ខ៖ មិនចង់ធ្វើអ្វីនោះទេគ្រាន់តែចង់លក់ដូរនៅមុខតែផ្ទះយើង
ចង់តែនៅលក់ដូរចង់តែនៅលក់ដូរនៅមុខផ្ទះចឹងទៅអោយបានមួយហូបចឹងណា។

កៈ លក់អីវ៉ាន់ចាបហួយអ៊ីន៎?

ខៈ ចាស!!

កៈ អ៊ី! អ៊ីចឹងអ៊ីជាចុងក្រោយអ៊ីមានពាក្យពេជ្រអ៊ីដើម្បីផ្ដែរផ្ដាំដល់ក្មេងជំនាន់ក្រោយ ប្រាប់ដល់ក្មេងដែលគេបានស្ដាប់សំលេងរបស់អ៊ីចឹង ?

ខៈផ្ដាំដល់ក្មេងជំនាន់ក្រោយនឹងថាអោយខំតស៊ូថាដឹងគុណអ្នកដែលគេបានចិញ្ចឹមបីបាច់យើងមកតាំងពីតូចចឹងហើយកុំអោយធ្វើបាបគាត់ព្រោះគាត់ខំចិញ្ចឹមយើងចឹងទៅថាដឹងគុណគាត់ថាអ្នកមានគុណនឹងគាត់លំបាកវេទនាយ៉ាងណាទំរាំតែចិញ្ចឹមកូនបានមួយៗណាដូចកូនរបស់ខ្ញុំចឹងថាចិញ្ចឹមទំរាំបានមួយៗមកស៊ូចង់តែងាប់ទំរាំបានកូន ពេលខ្លះយើងចង់សុខចិត្តអត់អោយតែបានកូនទំរាំកូនបានប៉ុណ្ណឹង កូនខ្ញុំមួយៗនឹងវាបានដឹងពីការលំបាករបស់ឪពុកម្ដាយមួយៗចឹងហើយចង់អោយកូនខ្ញុំនឹងក្រោយនឹងដឹងថាកុំអោយធ្វើបាបម្ដាយឪពុកអីចឹងទៅព្រោះទំរាំតែចិញ្ចឹមកូនបានមួយៗនឹងវាពិបាកណាស់ទំរាំតែបានដល់កូនធំ។ ចឹងខ្ញុំមានការផ្ដាំផ្ញើរតែប៉ុណ្ណឹងតែអូន។

កៈ ចាស!!អរគុណច្រើនថ្ងៃនេះដែលអ៊ីបានផ្ដល់ការសំភាសន៏ចឹងខ្ញុំសូមអនុញ្ញាតដើម្បីនឹងដាក់សំលេងរបស់អ៊ីទៅក្នុងវេបសាយរបស់ខាងសាលា។

ខៈ ចាស!! ចាស!!

កៈ ចាស ចឹងអរគុណអ៊ី!!!